# របាយការណ៍សង្ខេប៖

# សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មរបស់ប្រទេសកម្ពុជា

របាយការណ៍សង្ខេប លីកាដូ

ខែកក្កដា ឆ្នាំ២០១២

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

របាយការណ៍នេះ បោះពុម្ពក្រោមជំនួយឧបត្ថម្ភ
ផ្នែកហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប

សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការលីកាដូ ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបឡើយ។

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវ បាន បង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារ សិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈ រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរៈ

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្សៈ**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការ ប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារៈ** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានា ថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រៈ** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រី ពន្ធនាគារចំនួន១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូន ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។
- **សេវាកម្មសង្គមកិច្ចៈ** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំ ដល់សាធារណជនអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្ដាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្ដូរសង្គម និងគោរពច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើប អង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយ ស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជា របាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org

# មាតិកា

**សេចក្តីសង្ខេប** ........................................ ១
**ការវិភាគ៖ បញ្ហាចំបងៗដែលកើតមាននៅក្នុងច្បាប់ភូមិបាល** .............. ៥
បុព្វកថា: ការដណ្តើមដីធ្លីក្នុងប្រទេសកម្ពុជា បានមកដល់ចំណុចគួរឲ្យចាប់អារម្មណ៍បំផុត ........................................ ៥
ភាពកាត់ផ្តាច់ពីគ្នា និងភាពគ្រោះថ្នាក់: តួនាទីអង្គការអន្តរជាតិ .............. ៧
បទឧក្រិដ្ឋ និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះទង្វើណាមួយក៏ដោយ ដែលខុសពីលក្ខខណ្ឌតម្រូវរបស់ច្បាប់ដែលពិបាកនឹងធ្វើបាន .............. ៩
តំបន់អភិវឌ្ឍន៍កសិកម្ម: ការប្រមូលផ្តុំដោយមិនស្ម័គ្រចិត្ត .............. ៩
លក្ខខណ្ឌតម្រូវនៃការអភិរក្សដី និងធនធានដី .............. ១១
ការជួលដីកសិកម្ម: សម្បទានដីថ្មីមួយដែលមិនមានការគ្រប់គ្រងដោយច្បាប់ .......... ១២
អជ្ញាប័ណ្ណបំលែងដី: ការបំផ្លាញចោលសិទ្ធិកម្មសិទ្ធិឯកជន .............. ១៣
មូលដ្ឋានច្បាប់ចំពោះការធ្វើអោយរួញរាដល់វិធីធ្វើកសិកម្មពនេចរ .............. ១៥
ក្នុងករណីមានជម្លោះទាក់ទងនឹងកិច្ចសន្យា គឺកសិករជាអ្នកចាញ់ទាំងស្រុង............ ១៥
ការសរសេរមិនច្បាស់លាស់ថា សកម្មភាពកសិកម្ម "មាននិរន្តរភាព" លើដីឯកជន.... ១៦
**អនុសាសន៍** ........................................ ១៦

# សេចក្តីសង្ខេប

**សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មរបស់ប្រទេសកម្ពុជា។ គំរាមកំហែងដកយកសិទ្ធិកម្មសិទ្ធិលើទ្រព្យសម្បត្តិឯកជន និងលុបចោលរាល់លក្ខខណ្ឌកំហិតទាំងអស់លើដីសម្បទានសេដ្ឋកិច្ច។**

កាលពីចុងឆ្នាំកន្លងទៅ រដ្ឋាភិបាលកម្ពុជាបានបញ្ចេញដោយស្ងាត់ៗនូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម ដែលពង្រាងនេះ មានផលវិបាកផ្សេងៗលើអ្នកកាន់កាប់ដីឯកជន។ សេចក្តីព្រាងច្បាប់នេះ អាចយកមកប្រើបាន សម្រាប់អ្នកទាំងឡាយណាដែលស្វះស្វែងរកការការពារស្របច្បាប់ ចំពោះដីដែលដណ្តើមយកមកបាន និងលទ្ធភាពកាន់តែច្រើនឡើងដើម្បីយកផលប្រយោជន៍ និងផលចំណេញជាបុគ្គលពីដី និងធនធានរបស់ប្រទេសកម្ពុជា។ ជាការព្រួយបារម្ភបំផុតនោះ គឺច្បាប់នេះបង្កើតនូវការទទួលខុសត្រូវខាងបទល្មើសព្រហ្មទណ្ឌចំពោះអំពើណាដែលរំលោភតិចតួចក្លាយទៅជាបទឧក្រិដ្ឋធ្ងន់ធ្ងរ។ ហេតុដូច្នេះ ទិដ្ឋភាពនៃសេចក្តីព្រាងច្បាប់នេះ ត្រូវតែត្រួតពិនិត្យជាបន្ទាន់ និងកែប្រែឲ្យបានច្រើនមានដូចខាងក្រោមនេះ៖

> មាត្រា៥៤: ជនណាដែលប្រព្រឹត្តល្មើស ឬមិនបានអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬលិខិបទដ្ឋានគតិយុត្តណាមួយ ក្រោមច្បាប់នេះ ដែលតម្រូវអោយធ្វើ ឬ មិនធ្វើអ្វីមួយ ឬ បទបញ្ជាដែលត្រឹមត្រូវតាមច្បាប់របស់មន្ត្រីអគ្គនាយកដ្ឋានកសិកម្មដែលបានចេញទៅអោយជននោះ គឺជាកំហុសថ្នាក់ទី៣។
>
> [...]
>
> បុគ្គលដែលបានកាត់ទោសពីបទល្មើស ថ្នាក់ទី៣ ក្រោមច្បាប់នេះ ត្រូវជាប់ពន្ធនាគារ ចាប់ពីមួយខែដល់មួយឆ្នាំ និងត្រូវផាកពិន័យចាប់ពី ១.000.000 រៀល ទៅ ១0.000.000 រៀល

ជាបឋម និងជាចម្បង ដូចដែលបានកត់សំគាល់ខាងលើ សេចក្តីព្រាងច្បាប់ថ្មីនេះ ដាក់អោយមានការទទួលខុសត្រូវខាងបទល្មើសព្រហ្មទណ្ឌ។ សេចក្តីព្រាងច្បាប់ថ្មីនេះ ផ្តល់អោយមានការដាក់ទោសជាប់ពន្ធនាគាររហូតដល់មួយឆ្នាំ ចំពោះអំពើរំលោភណាមួយ ទៅលើច្បាប់នេះ ផ្ទាល់លើអនុក្រិត្យណាមួយ ដែលចេញក្រោមច្បាប់នេះ ឬ សូម្បីតែបទបញ្ជានានាដែលចេញ ដោយអគ្គនាយកដ្ឋានកសិកម្ម (GDA) ដែលជាស្ថាប័នមួយស្ថិតក្រោមក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ក្រសួងកសិកម្ម)។ ដោយភាពមិនច្បាស់លាស់យ៉ាងខ្លាំងនៃកាតព្វកិច្ចជាច្រើនដែលបង្កើតឡើងក្រោមច្បាប់នេះ មានដូចជា លក្ខខណ្ឌតម្រូវថា អ្នកកាន់កាប់ដីឯកជន ធានាការប្រើប្រាស់ដីរបស់ខ្លួនអោយមាន "និរន្តរភាព" តាមការតម្រូវរបស់អគ្គនាយកដ្ឋានកសិកម្ម ដូច្នេះការដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបែបនេះ មិនសមស្របទាំងស្រុង និងងាយបង្កអោយមានការរំលោភបំពានយ៉ាងខ្លាំង។

ទីពីរ សេចក្តីព្រាងច្បាប់នេះ ផ្តល់អោយមានការបង្កើតដោយភាពស្រពេចស្រពិលនូវ "តំបន់អភិវឌ្ឍន៍កសិកម្ម" (ADAs) ដឹកនាំដោយរដ្ឋាភិបាល ដែលរួមមានទាំងដីកាន់កាប់ដោយឯកជននូវចំនួនមិនកំណត់គ្រប់ទំហំ។ តំបន់អភិវឌ្ឍន៍កសិកម្ម ត្រូវបានបង្កើតឡើង ដោយមានកិច្ចព្រមព្រាងពីអ្នកកាន់កាប់ដីដែលទទួលផលប៉ះពាល់ ដោយមិនមាននិយមន័យច្បាស់លាស់ "ភាគច្រើនបំផុតសមរម្យ" ដែលស្ថិតក្នុងតំបន់ដែលស្នើបង្កើតនោះ។ ផែនការជាក់លាក់ និងមាតិកា ដែលគ្របដណ្តប់លើតំបន់ទាំងនោះ ត្រូវបានទុកអោយចេញតាមរយៈប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលដូចគ្នានឹងបទបញ្ញត្តិទាក់ទងនឹងការពិគ្រោះយោបល់ជាមួយអ្នកកាន់កាប់ដី មុនការអនុវត្តជាកំហិតនូវផែនការអភិវឌ្ឍន៍នៅតំបន់នោះ។ នៅពេលដែលផែនការបែបនេះ បានរៀបចំបំពេញចប់សព្វគ្រប់ហើយ ភារកិច្ចដើម្បីអនុវត្តផែនការនេះ ត្រូវបានកំណត់តាមរយៈកិច្ចព្រមព្រាងនៃអ្នកកាន់កាប់ដីភាគច្រើនបំផុត។ ការខកខានអនុវត្តសកម្មភាពនានា ដូចដែលមានរៀបរាប់ក្នុងផែនការអាចនឹងនាំអោយមានការកាត់ទោសពីបទព្រហ្មទណ្ឌ និងជាប់ពន្ធនាគារ ដោយទោះបីជាអ្នកកាន់កាប់ដី មិនបានយល់ព្រមទៅនឹងការបង្កើតតំបន់ ឬទៅនឹងផែនការនោះក៏ដោយ។ គម្រោងទាំងមូលត្រូវបានផ្តួចផ្តើម និងចាត់ចែងដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ មិនមានបទបញ្ញាត្តិណាមួយដែលអនុញ្ញាតឲ្យបញ្ចប់ ឬធ្វើឲ្យផុតកំណត់របស់តំបន់អភិវឌ្ឍន៍កសិកម្ម ឬធ្វើឲ្យដីដែលកាន់កាប់ដោយឯកជនរបស់តំបន់នោះ ត្រូវបានច្រានចេញពីផែនការអភិវឌ្ឍ។

ទីបី សេចក្តីព្រាងច្បាប់ តម្រូវថា អ្នកកាន់កាប់ដីឯកជនទាំងអស់ ត្រូវចាត់វិធានការដើម្បីទប់ស្កាត់ ឬបំលែងអោយ "ដីបាត់បង់គុណភាព ឬឱនភាពដី"។ បើសិនជាសកម្មភាពបែបនេះ មិនត្រូវបានចាត់ឡើងដើម្បីធ្វើអោយមន្ត្រីរដ្ឋាភិបាលទទួលយកបានទេ ច្បាប់ផ្តល់អោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទនូវអំណាច ដើម្បីចាត់វិធានការទៅលើអ្នកកាន់កាប់ដីនោះ។ ឧទាហរណ៍ដូចជា ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រោមច្បាប់នេះ អាចកំណត់សម្រេចបំផ្លាញដំណាំចោល ដោយគ្មានការផ្តល់សំណង ឬអាចផ្តល់អោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ "ចាត់ចែង" ទាំងស្រុងដោយសេរីលើដីដែលប្រព្រឹត្តល្មើស។

មិនមានការកំណត់និយមន័យ ឬដាក់កំហិតតាមបទបញ្ញត្តិ ដែលនិយាយអំពីការដាក់បន្ទុក ឬតម្លៃសមស្របនោះទេលើ "ដីបាត់បង់គុណភាព ឬដីមានឱនភាព" ឬក៏សកម្មភាពនានា ដែលអាចតម្រូវអោយធ្វើការទប់ស្កាត់ ឬជួសជុលការខូចខាតដីទាំងនេះ។ បទបញ្ញត្តិនិយាយអំពីដំណើរការប្តឹងជំទាស់ក៏មិនមានផងដែរ ហើយក៏មិនមានការណែនាំកំណត់អំពីឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់រដ្ឋាភិបាលទាក់ទងនឹងលក្ខខណ្ឌតម្រូវសម្រាប់ការអភិរក្សធនធានដីនោះទេ។ ជាថ្មីម្តងទៀត បើសិនជាអ្នកកាន់កាប់ដីខកខានគោរពតាមបទបញ្ញា ដែលចេញដោយរដ្ឋាភិបាល នោះពួកគេអាចប្រឈមនឹងការកាត់ទោសបទព្រហ្មទណ្ឌ ដែលជាលទ្ធផលនឹងនាំអោយមានការពិន័យជាប្រាក់យ៉ាងច្រើន ឬជាប់ពន្ធនាគារ។

ទីបួន សេចក្តីព្រាងច្បាប់ បង្កើតនូវគម្រោងថ្មីមួយទាំងស្រុងនៃ "ការជួលដីកសិកម្ម" ដែលដាក់ជំនួសលើលក្ខខណ្ឌកំហិត និងការការពារនាពេលបច្ចុប្បន្នទាំងអស់ ដែលបានតម្រូវអោយធ្វើចំពោះដីសម្បទានសេដ្ឋកិច្ច ក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រិត្យពាក់ព័ន្ធ។ ឧទាហរណ៍ នៅក្នុងច្បាប់នេះ មិនមានការកំណត់អំពីទំហំ ឬរយៈពេលអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬការពិគ្រោះយោបល់ជាមុន ឬលក្ខខណ្ឌនៃការព្រមព្រាងជាមុនទាក់ទងនឹងការជួលដីកសិកម្មបែបនេះទេ។

ទីប្រាំ សេចក្តីព្រាងច្បាប់ តម្រូវដល់ម្ចាស់ដីទាំងអស់ អោយរកឲ្យបាន "អជ្ញាប័ណ្ណបំលែងដី" មុនពេលនៃការចាប់ផ្តើមប្រើប្រាស់ដីផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ សម្រាប់គោលបំណងកសិកម្ម ឬបញ្ឈប់ការប្រើប្រាស់ដីនោះ។ ម្តងទៀត គឺមិនមានទំហំអប្បរមា ឬបទដ្ឋានកំណត់ពីការប៉ះពាល់សម្រាប់កម្រិតលើបន្ទុកនៃលក្ខខណ្ឌតម្រូវនេះទេ។ សេចក្តីព្រាងច្បាប់នេះ ក៏មិនបានផ្តល់ការណែនាំសម្រាប់ស្ថាប័នអន្តរក្រសួងថ្មី ដែលបង្កើតឡើងសម្រាប់អោយទទួលខុសត្រូវក្នុងការអនុញ្ញាតយល់ព្រម ឬបដិសេធការផ្តល់អជ្ញាប័ណ្ណបែបនេះ។ សេចក្តីព្រាងច្បាប់នេះ ក៏មិនមាននីតិវិធីសម្រាប់ដំណើរការប្តឹងជំទាស់នោះដែរ។ ពង្រាងនេះ ដាក់អោយទៅជាការខុសច្បាប់ចំពោះម្ចាស់ដី ដែលអនុវត្ត ឬបញ្ឈប់ការអនុវត្តសកម្មភាពកសិកម្មលើដីរបស់ខ្លួន មុនពេលទទួលបានអជ្ញាប័ណ្ណហើយ ដែលការខុសច្បាប់បែបនេះប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មិនមានអ្វី ដែលចង្អុលបង្ហាញថា សូម្បីតែសួនច្បារដំណាំជាលក្ខណៈគ្រួសារត្រូវបានលើកលែងនោះទេ បើពិនិត្យមើលលើពាក្យពេជន៍ដែលសរសេរនាពេលបច្ចុប្បន្នក្នុងសេចក្តីព្រាងច្បាប់នេះ។

ទីប្រាំមួយ សេចក្តីព្រាងច្បាប់ក៏មិនបានលើកទឹកចិត្ត និងសូម្បីតែរាំងក៏មិនអាចធ្វើទៅបានដែរ ដល់ការប្រើប្រាស់ជាបន្តនៃវិធីធ្វើកសិកម្មពនេចរជាប្រពៃណីក៏ដោយ។

ទីប្រាំពីរ សេចក្តីព្រាងច្បាប់ បញ្ចូលដោយមិនសមស្របនូវបទបញ្ញត្តិទាក់ទងនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដោយទោះបីជាជាក់ស្តែង ប្រធានបទនេះ ត្រូវបានគ្របដណ្តប់យ៉ាងទូលំទូលាយដោយក្រមរដ្ឋប្បវេណី និងអនុក្រិត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏ដោយ។ នៅក្នុងហេតុការណ៍ជម្លោះណាមួយរវាងកសិករ និងភាគីអ្នកទិញផលកសិកម្ម សេចក្តីព្រាងច្បាប់នេះផ្តល់យ៉ាងជាក់លាក់ថា ភាគីអ្នកទិញជាអ្នកមានព្រៀប គឺភាគីអ្នកទិញមានសិទ្ធិក្នុងការកំណត់បរិមាណនិងតម្លៃជាក់លាក់មួយ និងលក្ខខណ្ឌតាមកិច្ចសន្យាដ៏មានសក្តានុពលសំខាន់ៗជាច្រើនទៀត។

ជាចុងក្រោយ សេចក្តីព្រាងច្បាប់នេះអនុញ្ញាតអោយរដ្ឋាភិបាល មានឆន្ទានុសិទ្ធិដែលគ្មានដែនកំណត់ក្នុងការច្បាមយកដីដែលមានមនុស្សរស់នៅមកបង្កើតជា "តំបន់អភិរក្សជីវចំរុះកសិកម្ម"។

នៅទីបំផុត សេចក្តីព្រាងច្បាប់នេះ បង្ហាញនូវការគំរាមកំហែងដ៏ធ្ងន់ធ្ងរលើសិទ្ធិកម្មសិទ្ធិឯកជន ជាពិសេសលើកសិករដែលមានមុខរបរខ្នាតតូច។ សេចក្តីព្រាងច្បាប់នេះ ក៏ដោះស្រាយបានតែបន្តិចបន្តួច ឬមិនបានដោះស្រាយអ្វីទាល់តែសោះ ចំពោះបញ្ហាស្នូលរបស់ប្រទេសកម្ពុជាទាក់ទងនឹងការអភិវឌ្ឍកសិកម្ម និងការរំលោភសិទ្ធិដីធ្លី។

# ការវិភាគ៖ បញ្ហាចំបងៗដែលកើតមានលើច្បាប់ភូមិបាល

## បុព្វកថាៈ ការដណ្តើមដីធ្លីក្នុងប្រទេសកម្ពុជា បានមកដល់ចំណុចគួរឲ្យចាប់អារម្មណ៍បំផុត

នាប៉ុន្មានឆ្នាំថ្មីៗនេះ ប្រជាពលរដ្ឋកម្ពុជារាប់ពាន់គ្រួសារ បានបាត់បង់ដីធ្លីរបស់អ្នកទាំងអស់នោះ ដែលដីទាំងនោះបានធ្លាក់ចូលទៅក្នុងដៃអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងអ្នកមានអំណាច។ នៅក្នុងទីក្រុងភ្នំពេញ និងក្នុងខេត្តចំនួន១២ ដែលអង្គការ លីកាដូធ្វើការងារ ដែលគិតទៅប្រហែលជាពាក់កណ្តាលប្រទេស គឺមានប្រជាពលរដ្ឋច្រើនជាង ៤០០,០០០នាក់ បានរងផលប៉ះពាល់ដោយការដណ្តើមដីធ្លី និងការបណ្តេញចេញតាំងពីឆ្នាំ២០០៣ មក។ ក្នុងឆ្នាំ២០១១ តែប៉ុណ្ណោះ មានប្រជាពលរដ្ឋច្រើនជាង ១១,០០០ គ្រួសារទៅហើយ ដែលបានរងការប៉ះពាល់ដោយទំនាស់ដីធ្លីនាពេលបច្ចុប្បន្ននេះ។

ចំណែកដ៏សំខាន់មួយនៃការកើនឡើងនូវទំនាស់ដីធ្លីនាពេលថ្មីៗនេះ គឺការកើនឡើងនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលជាការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រយៈពេលវែងមួយ ហើយដែលជាធម្មតាមានរយៈពេលរហូត ៩៩ ឆ្នាំ។ ដីសម្បទានសេដ្ឋកិច្ច មានគោលបំណងលើកស្ទួយ ការអភិវឌ្ឍន៍កសិឧស្សាហកម្ម។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីលក្ខខ័ណ្ឌនៃការជួល និងការចរចា ក៏ដូចជាព័ត៌មានអំពីការប៉ាន់ប្រមាណលើចំណូលថវិការដ្ឋ ឬការរំពឹងទុកអំពីកំណើនការងារដែលទទួលបានមកពីដីសម្បទានទាំងអស់ គឺកំរ ឬមិនដែលត្រូវបានបង្ហាញ ឬពិភាក្សាជាសាធារណៈនោះទេ។ កង្វះតម្លាភាពមានវិសាលភាពធំធេងណាស់ជុំវិញការជួលដីទៅអោយក្រុមហ៊ុនសាជីវកម្មឯកជនដែលជាសក្តានុពលទទួលបានផលចំណេញខ្ពស់។

គិតមកដល់ត្រឹមខែកុម្ភៈ ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានជួលផ្ទៃដីយ៉ាងតិចណាស់ទំហំ ២,០៣៣,៦៦៤ ហិកតា អោយទៅក្រុមហ៊ុនឯកជនក្រោមគម្រោងសម្បទានរបស់ខ្លួន។ គ្រាន់តែក្នុងឆ្នាំ២០១១ តែប៉ុណ្ណោះ មានផ្ទៃដីប្រហែលជា ៨០០,០០០ហិកតាទៅហើយ ដែលត្រូវបានផ្តល់ជាដីសម្បទាន។ ការកើនឡើងដ៏គំហុកនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ ធ្វើអោយដីដាំដំណាំបាននោះមាននៅសល់បន្តិចបន្តួចក្នុងប្រទេសកម្ពុជា ដែលភាគច្រើនលើសលុបត្រូវបានកាន់កាប់ដោយក្រុមហ៊ុនឯកជនតាមរយៈកិច្ចសន្យាជួលរយៈពេលវែង។

អង្គការសិទ្ធិមនុស្សជាច្រើន រួមមានអង្គការលីកាដូ បានកត់សម្គាល់អំពីការកើនឡើងជាច្រើននូវចំនួននៃការតវ៉ាទាក់ទងនឹងការរំលោភសិទ្ធិដីធ្លីនាពេលថ្មីៗនេះ។ ការតវ៉ាទាំងនេះជាច្រើនបានធ្វើឲ្យមានអំពើហិង្សាកើតឡើង។ យ៉ាងតិចណាស់មានឧប្បត្តិហេតុចំនួនប្រាំបី ពាក់ព័ន្ធនឹងកងកម្លាំងយោធា និងនគរបាលប្រដាប់អាវុធ បាញ់ដោយអាវុធក្នុងអំឡុងការតវ៉ារឿងដីធ្លី ឬបាញ់ប្រហារ

ទៅលើសកម្មជនសិទ្ធិដីធ្លី ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១១ កន្លងទៅនេះ។ មានមនុស្សសរុបចំនួន ១៩នាក់ បានរងរបួស នៅក្នុងការតវ៉ាទាំងអស់នោះ ដែលរួមមានមនុស្ស ៧ នាក់ រងរបួសដោយគ្រាប់កាំភ្លើង។ ហើយមានសកម្មជនបរិស្ថានកម្ពុជាដ៏លេចធ្លោមួយរូប គឺលោក ឈុត វុទ្ធី ត្រូវបានបាញ់សម្លាប់ ដោយមន្ត្រីកងរាជអាវុធហត្ថ ខណៈដែលគាត់ថតរូបភាពជាភស្តុតាងនៃការកាប់ឈើខុសច្បាប់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២។ នៅក្នុងឧប្បត្តិហេតុថ្មីៗមួយទៀតនាថ្ងៃទី១៦ ខែឧសភា មានកុមារីអាយុ១៤ឆ្នាំត្រូវបានបាញ់ស្លាប់នៅពេលដែលមានការបណ្តេញចេញ ដោយកំលាំងយោធាយ៉ាងច្រើន។

ទោះបីជាឧប្បត្តិហេតុភាគច្រើន ត្រូវបានចងក្រងជាឯកសារតាមរូបភាពវីដេអូ ឬ រូបថតក៏ដោយ ក៏ការចាប់ខ្លួនត្រូវបានធ្វើឡើងតែក្នុងករណីពីរប៉ុណ្ណោះ។ មកដល់បច្ចុប្បន្ននេះ គ្មានជនល្មើសណាម្នាក់ដែលប្រព្រឹត្តអំពើហិង្សាទៅលើជនស៊ីវិលត្រូវបានកាត់ទោសអំពីបទល្មើសនោះទេ។ មន្ត្រីរដ្ឋាភិបាលបានរាយការណ៍ថា ការស្លាប់របស់កុមារីមិនបាច់មានការស៊ើបអង្កេតទេ។

ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្ត្រី១៣នាក់ ដែលជាសកម្មជនសិទ្ធិលំនៅឋាន និងដីធ្លី មកពីតំបន់បឹងកក់ទីក្រុងភ្នំពេញត្រូវបានចាប់ខ្លួនដោយហិង្សាកំឡុងពេលកំពុងតវ៉ាប្រឆាំងដោយអហិង្សាមួយនៅអតីតតំបន់បឹងកក់។ បន្ទាប់ពីឃុំខ្លួនអស់រយៈពេល៤៨ម៉ោងក្រោយមក ហើយនឹងរយៈពេលមួយម៉ោងក្រោយចោទប្រកាន់ត្រូវបានធ្វើឡើង ស្ត្រីទាំងនោះត្រូវបានចោទប្រកាន់យ៉ាងច្រើនករណី និងកាត់ទោសពីបទ "បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ" និង"បទប្រឆាំងអាជ្ញាធរសាធារណៈ ដែលមានស្ថានទំងន់ទោស"។ ស្ត្រីទាំងនោះត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗ២ឆ្នាំកន្លះ ដែលក្នុងនោះមាន ៦ នាក់មានការព្យួរទោសនូវផ្នែកខ្លះ។ ការកាត់ទោស ត្រូវបានប្រព្រឹត្តឡើងតែរយៈពេលបីម៉ោងប៉ុណ្ណោះ។ មេធាវីស្ត្រីទាំង១៣ នាក់មិនត្រូវបានអនុញ្ញាតិឲ្យពិនិត្យមើលឯកសារសំណុំរឿង ឬក៏ភស្តុតាងឡើយ ការស្នើសុំក្នុងការពន្យាពេលកាត់សេចក្តី ត្រូវបានបដិសេធ ហើយការនិយាយជាមួយកូនក្តីក៏មិនត្រូវបានអនុញ្ញាតដែរ បន្ទាប់ពីការចោទប្រកាន់ដែលត្រូវបានប្តឹង ហើយសូម្បីតែការស្នើសុំសាក្សីការពារជនជាប់ចោទរបស់មេធាវី ក៏ត្រូវបានបដិសេធផងដែរ។ រាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងនោះ មិនត្រឹមតែត្រូវបានធានាដោយច្បាប់អន្តរជាតិនោះទេ ហើយថែមទាំងត្រូវបានដាក់បញ្ចូលយ៉ាងជាក់ស្តែងទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ ដោយអត្ថបទសង្ខេបនេះ គឺកំពុងត្រូវបានតាក់តែងបញ្ចប់ ស្ត្រីទាំងនោះ នឹងត្រៀមខ្លួនចូលសវនាការសាលាឧទ្ធរណ៍នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២។

ខណៈនេះដែរ យោងតាមអង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) មានប្រជាពលរដ្ឋកម្ពុជា ៦៦ ភាគរយពឹងផ្អែកលើកសិកម្មសម្រាប់ជីវភាពរស់នៅរបស់អ្នក

ទាំងនោះ ហើយមានប្រជាពលរដ្ឋកម្ពុជាប្រហែលជា ៣លាននាក់ ប្រឈមនឹងកង្វះអាហាររូបត្ថម្ភ។ មាន ៣៧ ភាគរយនៃកុមារក្នុងប្រទេសកម្ពុជា ខ្វះអាហាររូបត្ថម្ភដល់កម្រិតដែលប៉ះពាល់ធ្ងន់ធ្ងរដល់ការការរីកលូតលាស់របស់អ្នកទាំងនោះ។

## ភាពកាត់ផ្តាច់ពីគ្នា និងភាពគ្រោះថ្នាក់: តួនាទីអង្គការអន្តរជាតិ

នៅចំពោះមុខស្ថានភាពនេះហើយ ដែលអង្គការ FAO បានអនុម័តថវិកាចំនួន ៩៩,០០០ ដុល្លារសហរដ្ឋអាមេរិក ផ្តល់អោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់គម្រោងមួយក្នុងរយៈពេលពេញមួយឆ្នាំ២០១១ ដើម្បីធ្វើសេចក្តីព្រាងច្បាប់ដីកសិកម្ម។ កាលពីពេលចាប់ផ្តើមរបស់គម្រោងមួយនេះ មានការអះអាងថា សេចក្តីព្រាងច្បាប់ មានគោលបំណងលើកស្ទួយការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ដែលនឹងបង្កើនដល់ផលិតភាព និងការអភិរក្សដី។ មានសេចក្តីរាយការណ៍ថា ចាប់តាំងពីខែធ្នូ ឆ្នាំ២០១០ មក FAO បានធ្វើពង្រាង និងកែប្រែច្បាប់នេះជាច្រើនដង ដោយមិនមានការពិគ្រោះយោបល់ដ៏មានសារៈសំខាន់ ឬការអោយយោបល់ពីដៃគូពាក់ព័ន្ធនានាឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានគេរាយការណ៍ថា បានរៀបចំនូវសិក្ខាសាលាជាច្រើនលើកផងដែរនៅក្នុងចុងឆ្នាំ២០១១កន្លងទៅនេះ។

មិនមានការពិគ្រោះយោបល់ជាសាធារណៈ ឬសិក្ខាសាលាណាមួយ ដែលដឹកនាំធ្វើដោយរដ្ឋាភិបាល ឬដោយសង្គមស៊ីវិល ដែលធ្វើឲ្យមានការកែប្រែណាមួយ នៅក្នុងសេចក្តីព្រាងច្បាប់ខែតុលា ឆ្នាំ២០១១ សម្រាប់ផ្សព្វផ្សាយជាសាធារណៈនោះទេ ដែលនេះគឺជាប្រធានបទសម្រាប់ការវិភាគនេះ។ មិនមានសេចក្តីព្រាងដទៃផ្សេងទៀតត្រូវបានគេផ្សព្វផ្សាយនោះទេ រហូតមកដល់ពេលនេះ។

> "ការមកដល់នៃអ្នកវិនិយោគទុនក្នុងវិស័យកសិកម្ម អាចបង្ហាញនូវឱកាសជាក់លាក់មួយចំនួន ប៉ុន្តែមានបញ្ហាប្រឈមធំៗជាច្រើនខាងសិទ្ធិមនុស្ស ហើយការវិនិយោគទុនដែលអាចប៉ះពាល់សិទ្ធិដីធ្លី គឺជាប្រភពនៃកង្វល់ដ៏ពិតប្រាកដ។ សិទ្ធិមនុស្សក្នុងការទទួលបានម្ហូបអាហារ នឹងត្រូវរងការរំលោភបំពាន បើសិនជាប្រជាពលរដ្ឋពឹងអាស្រ័យទាំងស្រុងលើដីធ្លីនោះ ដើម្បីជីវភាពរស់នៅរបស់ខ្លួនត្រូវបានកាត់ផ្តាច់ពីការប្រើប្រាស់ដីធ្លី ដោយគ្មានជម្រើសផ្សេងដែលសមស្របនោះទេ។ ប្រសិនបើជា ចំណូលក្នុងស្រុកមិនគ្រប់គ្រាន់សម្រាប់ទូទាត់ចំពោះតម្លៃ នៃការប៉ះពាល់ដែលកើតចេញពីការផ្លាស់ប្តូរទៅរកការផលិតម្ហូបអាហារសម្រាប់ការនាំចេញនោះទេ។ ឬប្រសិនបើជាចំណូលរបស់អ្នកកាន់កាប់ដីតូចតាចក្នុងស្រុកត្រូវបានធ្លាក់ចុះ បន្ទាប់ពីការមកដល់នៃទីផ្សារក្នុងស្រុកនូវម្ហូបអាហារមានតម្លៃថោក ដែលបានផលិតដោយភាពប្រកួតប្រជែងគ្នាខ្លាំងលើដីចំការទំហំធំៗ អភិវឌ្ឍន៍ដោយការមកដល់នៃអ្នកវិនិយោគទុន។ ក្នុងការសម្រេចលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ ដី ឬជួលដី ដែលមានទំហំធំៗ រដ្ឋគួរតែគិតគូពិចារណាទៅដល់សិទ្ធិរបស់អ្នកប្រើប្រាស់ដី នាពេលបច្ចុប្បន្ន នៅក្នុងតំបន់ដែលការវិនិយោគត្រូវបានធ្វើឡើង...។"
>
> - អ្នករាយការណ៍ពិសេសខាងសិទ្ធិទទួលបានម្ហូបអាហារ Oliver De Schutter-

ពាក់ព័ន្ធជាមួយគ្នាផងដែរ ធនាគារអភិវឌ្ឍន៍អាស៊ី ADB បានបញ្ចូលជា សូចនាករ ការប្រកាសដាក់អោយប្រើ និងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្មមួយ ដែលមិនទាន់កំណត់នៅឡើយនៅឆ្នាំ២០១៤ ទៅក្នុងគម្រោងដ៏ធំមួយមានចំណងជើងថា "កម្ពុជា: កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវអង្ករដោយបរិយាកាសងើបឡើងវិញ"។ គម្រោងនេះ ទទួលបាននូវការអនុម័តថវិការួចហើយ ចំនួន ១.៥ លានដុល្លារសហរដ្ឋអាមេរិក និងមានថវិកាបន្ថែម ដែលបានស្នើឡើងដ៏ច្រើនលើសលុបចំនួន ៥៥ លាន ដុល្លារសហរដ្ឋអាមេរិក។ ដើម្បីអនុវត្តសេចក្តីព្រាងច្បាប់នេះទាន់ពេលវេលា អោយបំពេញទៅតាមសូចនាកររបស់គម្រោងនេះ និងដោយយោលទៅលើដំណាក់កាលដែលសេចក្តីព្រាងច្បាប់នេះ ស្ថិតនៅនាពេលបច្ចុប្បន្ន នោះកាលបរិច្ឆេទដែលបានកំណត់ឡើង គឺជាការដាក់សំពាធលើពេលវេលាដ៏ខ្លាំងមួយ ទៅលើរដ្ឋាភិបាល ក្នុងការជម្រុញសេចក្តីព្រាងច្បាប់ ក្នុងរយៈពេលពេញមួយឆ្នាំនេះ។ លើសពីនេះទៀត សូចនាកររបស់ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់អោយរដ្ឋាភិបាលនូវការដោះសារយករួចខ្លួនមួយ ដោយការបង្កើត និងជំរុញអោយចេញនូវបញ្ញត្តិច្បាប់ដ៏លេចធ្លោមួយពោរពេញទៅដោយបទបញ្ញត្តិ ដែលជួយដល់ការរំលោភបំពាន។

## បទឧក្រិដ្ឋ និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះទង្វើណាមួយក៏ដោយ ដែលខុសពីលក្ខខណ្ឌតម្រូវរបស់ច្បាប់ដែលពិបាកនឹងធ្វើបាន

ក្រោមបទបញ្ញត្តិបទល្មើសព្រហ្មទណ្ឌក្នុងជំពូក១០ នៃសេចក្តីព្រាងច្បាប់នេះ ជនណាដែល "ប្រព្រឹត្តល្មើស ឬមិនបានអនុវត្តតាម" បទបញ្ញត្តិណាមួយនៃច្បាប់ *ចែងក្នុងអនុក្រិត្យ*ដែលចេញតាមច្បាប់នេះ ឬសូម្បីតែ *ចែងក្នុងបទបញ្ជារបស់អគ្គនាយកដ្ឋានកសិកម្ម* គឺមានកំហុសថ្នាក់ទី៣ ជាបទល្មើសដែលអាចមានទោសជាប់ពន្ធនាគាររហូតដល់មួយឆ្នាំ និងការពិន័យជាប្រាក់យ៉ាងច្រើន។ ក្រោមច្បាប់នេះ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌអាចផ្តួចផ្តើមឡើងដោយមន្ត្រីនៃអគ្គនាយកដ្ឋានកសិកម្ម។

មានបទបញ្ញាត្តិមួយថែមទៀតក្នុងសេចក្តីព្រាងច្បាប់នេះ ដែលគួរយកមកពិចារណា។ តាមមាត្រា ៥៩ គឺមិនមែនត្រឹមតែការប្រព្រឹត្តណាមួយដែលខុសពីច្បាប់ ឬបទបញ្ជាដែលចេញតាមច្បាប់នេះ ជាបទល្មើសនោះទេ ដូច្នេះនៅក្រោមច្បាប់នេះ មានទាំងអំពើដែលធ្វើអោយរាំងស្ទះ ឬនៅពីក្រោយ "នរណាម្នាក់ ឬមន្ត្រីណាមួយក្នុងការអនុវត្តអំណាច និងភារកិច្ចរបស់ខ្លួន"។ មិនមែនជាការពន្លឿសទេ ដើម្បីអោយគិតទៅឃើញថា ឧទាហរណ៍ អ្នកកាន់កាប់ដីណាដែលមិនឯកភាពជាមួយនឹងការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ឬសូម្បីតែសមាជិកអង្គការសង្គមស៊ីវិលដែលព្យាយាមតស៊ូមតិលើការយល់ដឹពីបញ្ហាទាក់ទងនឹងការអភិវឌ្ឍកសិកម្មក៏ដោយ ក៏អាចនឹងត្រូវគេនាំយកមកកាត់ទោសក្រោមបទបញ្ញត្តិនេះដែរ។

ជាការស្មានដោយលំបាកថាមានច្បាប់ព្រហ្មទណ្ឌណាមួយ ដែលអាចអនុញ្ញាតអោយមានឆន្ទានុសិទ្ធិ (សេរីភាពក្នុងការសម្រេច) ឬក៏អាចអោយមានការរំលោភបំពានលើសពីនេះទេ។ ការដាក់ឲ្យស៊ីសង្វាក់គ្នារវាងបទបញ្ញត្តិព្រហ្មទណ្ឌ ជាមួយច្បាប់មួយដែលមានបំណងលើកស្ទួយកសិកម្មប្រកបដោយសមត្ថភាព ប្រសិទ្ធិភាព និងនិរន្តរភាពជាការលំបាក ឬក៏មិនអាចធ្វើបាន។ យើងត្រូវតែកុំភ្លេចអាន និងចងចាំនៅក្នុងចិត្តថាសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មនេះដែលមានបទបញ្ញត្តិ ព្រហ្មទណ្ឌមានលក្ខណៈជ្រុលហួសហេតុ ដែលគ្មានហេតុផលសមស្របនោះទេ។

## តំបន់អភិវឌ្ឍន៍កសិកម្ម: ការប្រមូលផ្តុំដោយមិនស្ម័គ្រចិត្ត

ក្រោម មាត្រា៣ និង មាត្រា១៤ "តំបន់អភិវឌ្ឍន៍កសិកម្ម" (ADAs) អាចត្រូវបានបង្កើតឡើងដោយក្រសួងកសិកម្មនៅស្ទើរគ្រប់ទីកន្លែង ចំពោះដីកសិកម្មគ្រប់ទំរង់។ គោលបំណងនៃតំបន់នេះមានការរៀបរាប់ដោយមិនបានច្បាស់លាស់ថា ជាការបង្កើនផលិតភាព និងអភិវឌ្ឍន៍ផលិតផលកសិកម្មសម្រាប់ទីផ្សារ។

ឲ្យតែអ្នកកាន់កាប់ដីដែលទទួលផលប៉ះពាល់នេះ សុខចិត្តឯកភាពក្នុងការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម នោះមាត្រា១៥ "តម្រូវឲ្យមានត្រឹមតែមតិភាគច្រើនសមរម្យ" ប៉ុន្តែមតិភាគច្រើននោះបានកំណត់និយមន័យមិនច្បាស់លាស់ទេ[១]។ ដូច្នេះ ច្បាប់នេះចង់និយាយសំដៅថា អ្នកកាន់កាប់ដីឯកជន ដែលមិនឯកភាពបង្កើតតំបន់អភិវឌ្ឍន៍កសិកម្មនេះ យ៉ាងណាក៏ដោយក៏ត្រូវបានគេបង្ខំអោយចូល និងចូលរួមយ៉ាងសកម្មនៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្មជាមួយអ្នកទាំងអស់នោះដែរ។

ក្រោយការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ក្រោមជំពូកនេះ ច្បាប់ដាក់លក្ខខណ្ឌអោយរៀបចំផែនការអភិវឌ្ឍមួយ ដូចដែលបានចែងក្នុងមាត្រា ១៧ គឺតម្រូវឲ្យតែមានការឯកភាព ភាគច្រើនតែប៉ុណ្ណោះ និងបង្ខំកសិករខ្នាតតូច ដែលប៉ះពាល់ដោយការបង្កើតតំបន់នេះ គឺត្រូវតែចូលក្នុងតំបន់ដែលបង្កើតនោះ។ មិនមានបទបញ្ញត្តិណាមួយនិយាយកំហិត ឬកំណត់អំពីបំណង ឬមាតិកានៃផែនការអភិវឌ្ឍកសិកម្មនោះទេ។ មាត្រា១៧ ទុកអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំណត់ដោយប្រកាសរបស់ក្រសួង អំពីលក្ខណៈពិសេសដែលបានលំអិត និងមាតិកានៃផែនការអភិវឌ្ឍន៍តំបន់កសិកម្ម និងវិធីនៃការប្រឹក្សាជាមួយកសិករខ្នាតតូចក្នុងកំឡុងពេល នៃការរៀបចំ និងអនុវត្តផែនការនោះ។

> "រដ្ឋទាំងអស់ត្រូវតែការពារសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋ និងធានាថា ប្រជាពលរដ្ឋទាំងអស់នោះមិនត្រូវបានគេបណ្តេញចេញតាមអំពើចិត្តនោះទេ។ បើមិនដូច្នោះទេនោះ សិទ្ធិកាន់កាប់ដីធ្លីរបស់អ្នកទាំងអស់នោះត្រូវបានបាត់បង់ ឬត្រូវបានគេរំលោភ"
>
> - គោលការណ៍ណែនាំស្មគ្រ័ចិត្តលើអភិបាលកិច្ចដែលមានការទទួលខុសត្រូវការពីការកាន់កាប់ដីរុក្ខាប្រមាញ់ និងនេសាទ នៅក្នុងបរិបទសន្តិសុខស្បៀងជាតិ ដែលបានផ្សាយដោយអង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២-

បន្ទាប់មក មាត្រា១៨ ចែងថា អ្នកកាន់កាប់ដីធ្លីទាំងអស់នៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ដោយមិនគិតថា តើអ្នកទាំងនោះគាំទ្រការបង្កើតតំបន់ និង/ឬផែនការអភិវឌ្ឍតំបន់នោះទេ គឺត្រូវតែ "សហការ និងធ្វើការ" ដើម្បីអនុវត្តផែនការ និង"គោរពតាមការណែនាំ" របស់មន្ត្រីរដ្ឋាភិបាល។ ទោះបីជាច្បាប់បានចែងថា ការអនុវត្តស្រាប់គួរតែត្រូវបានគិតគូពិចារណាក៏ដោយ ក៏មិនមានអ្វីសម្រាប់រាំងផែនការអភិវឌ្ឍកសិកម្មពីការកែប្រែជំរើស និងវិធីដាំដំណាំរបស់កសិករខ្នាតតូចនោះទេ។ ជាឧទាហរណ៍ គ្រួសាររបស់កសិករ ដែលបានដាំដំណាំពោតអស់ជាច្រើនជំនាន់មកហើយ អាចនឹងត្រូវបង្ខំអោយប្តូរមកដាំស្រូវ ឬកៅស៊ូវិញ ហើយ

[១] នៅក្នុងឯកសារបកប្រែជាភាសាខ្មែរបច្ចុប្បន្ន ច្បាប់បានបញ្ញត្តិអំពីការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ដោយមានការយល់ស្របដោយមតិ "ភាគច្រើន" ធម្មតាពីអ្នកកាន់កាប់ដីដែលទទួលផលប៉ះពាល់ទាំងឡាយ។

នឹងមិនមានជម្រើសដើម្បីជំទាស់នឹងសេចក្តីសម្រេចបែបនេះទេ។ កសិករដែលមិនបានគោរពតាម និងអនុវត្តផែនការអភិវឌ្ឍ នឹងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ហើយអាចប្រឈមនឹងការជាប់ពន្ធនាគារក្រោមសេចក្តីព្រាងច្បាប់នេះ។ មិនមានបទបញ្ញត្តិណាមួយក្នុងច្បាប់នេះ ដែលទាក់ទងនឹងការបញ្ចប់ ឬផុតសុពលភាពនៃតំបន់អភិវឌ្ឍន៍កសិកម្ម ឬអនុញ្ញាតឲ្យអ្នកកាន់កាប់ដីឯកជនធ្វើការដកខ្លួនចេញដោយខ្លួនឯង ឬធ្វើការសុំលាលែងចេញឡើយ។

## លក្ខខណ្ឌតម្រូវនៃការអភិរក្សដី និងធនធានដី

សេចក្តីព្រាងច្បាប់ចែងថា អ្នកកាន់កាប់ដីគ្រប់រូប មានកាតព្វកិច្ចក្នុងការទប់ស្កាត់ការបាត់បង់គុណភាពដី ឬឱនភាពដី។ ការបាត់បង់គុណភាពដី ឬឱនភាពដីមិនត្រូវបានកំណត់និយមន័យទេ ហើយក៏មិនមានជាឧទាហរណ៍ណាមួយ នៃវិធានការជាសក្តានុពលដែលអាចចាប់បង្ខំទៅលើអ្នកកាន់កាប់ដីនោះដែរ។ បើសិនជា អ្នកកាន់កាប់ដីឯកជនខកខានចាត់វិធានការសមស្របតាមមាត្រា ២៤ នោះ អគ្គនាយកដ្ឋានកសិកម្មមានសិទ្ធិចូលទៅកាន់ទីតាំងដីនោះ ហើយចាត់វិធានការកែតម្រូវតាមបទបញ្ជារបស់ខ្លួន។

បទបញ្ជារបស់អគ្គនាយកដ្ឋានកសិកម្ម តាមមាត្រា ២៥ អាចមាននូវស្ទើរតែគ្រប់វិធានការនានា ដើម្បីចាត់ឡើងទៅលើទ្រព្យសម្បត្តិរបស់អ្នកកាន់កាប់ដីរួមមានៈ

- "ការដុត ការកាប់ ឬការបំផ្លាញប្រភេទរុក្ខជាតិ ដំណាំ នៅពេលដែលមន្ត្រីពាក់ព័ន្ធរកឃើញថា ជាការចាំបាច់ ឬសមស្រប..."
- "ការទាមទារនូវការរំលើង ឬការកាប់បំផ្លាញ ដោយគ្មានសំណងចំពោះដំណាំ ដែលបានដាំ ឬអនុញ្ញាតអោយដាំដោយល្មើសទៅនឹងបទបញ្ជាការពារធនធានដី" និង
- "ហាមឃាត់ រិតបន្តឹង និងត្រួតពិនិត្យការប្រើប្រាស់ដីកសិកម្ម"។

មិនមានការដាក់កំហិតអ្វីទាល់តែសោះ ទៅលើឆន្ទានុសិទ្ធិរបស់អគ្គនាយកដ្ឋានកសិកម្មនៅពេលដែលមកដល់ចំណុច ដែលត្រូវអនុវត្តបទបញ្ជារបស់អគ្គនាយកដ្ឋានកសិកម្មទាក់ទងនឹងការអភិរក្សធនធានដី។ លើសពីនេះទៀត មិនមានបទបញ្ញត្តិណាមួយដែលទាក់ទងនឹងឱកាសសម្រាប់វិធានការជាកំណត់លើការកែលំអរដីនោះទេ។ មិនមែនជាការពន្លើសទេ បើនិយាយថាកសិករខ្នាតតូចនឹងមិនមានលទ្ធភាពបង់ប្រាក់សម្រាប់កិច្ចខិតខំប្រឹងប្រែងអភិរក្សធនធានដី ក្នុងទំរង់ដ៏ធំមួយដែលដឹកនាំដោយអគ្គនាយកដ្ឋានកសិកម្មនោះទេ។ ផលវិបាកដែលកើតចេញពីភាពមិនជោគជ័យនេះ អាចនាំមកដល់នូវការជាប់ពន្ធនាគារ។

## ការជួលដីកសិកម្ម: សម្បទានដីថ្មីមួយដែលមិនមានការគ្រប់គ្រងដោយច្បាប់

ជំពូក៨ បង្កើតនូវគម្រោងថ្មីមួយទាំងស្រុងសម្រាប់ "ការជួលដីកសិកម្ម" ដែលបានកំណត់ដោយបញ្ចូលទាំងការជួលដោយរដ្ឋាភិបាលនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅអោយក្រុមហ៊ុន ដែលមានបំណង "អនុវត្តសកម្មភាពការងារកសិកម្មលើដីដែលបានជួល"។

ពាក្យដែលបានសរសេរនេះ ហាក់ដូចជាបានធ្លាប់ដឹងលឺរួចមកហើយ។ ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងថា "អនុញ្ញាតឲ្យអ្នកទទួលប្រយោជន៍កាប់ឆ្ការទាញយកផលដោយធ្វើអាជីវកម្មកសិឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា"[២] (មាត្រា ៤៩)។

សំណួរត្រឹមត្រូវមួយអាចសួរមកថា: ហេតុអ្វីបានជារដ្ឋាភិបាលកំណត់និយមន័យឡើងវិញក្រោមចំណងជើងផ្សេងនូវអ្វីដែលបានបង្កើតរួចទៅហើយកាលពីមួយទសវត្សរកន្លងទៅនេះ។ ចម្លើយស្រួលបំផុត គឺ "ការជួលដីកសិកម្ម" គឺជាទម្រង់ថ្មីមួយនៃសម្បទានដីសេដ្ឋកិច្ច ដែលមិនជាប់ជំពាក់ជាមួយលក្ខខណ្ឌអ្វីឡើយ។

និយាយម្យ៉ាងទៀតថា សេចក្តីព្រាងច្បាប់នេះ មិនស្របជាមួយនឹងលក្ខខណ្ឌតម្រូវដីសម្បទានសេដ្ឋកិច្ច ដូច្នេះសេចក្តីព្រាងច្បាប់នេះជំនួសលក្ខខណ្ឌ ដែលបានដាក់ចំពោះដីសម្បទានសេដ្ឋកិច្ច ហើយលក្ខខណ្ឌទាំងនេះក៏មានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រិត្យស្តីពីដីសម្បទាន សេដ្ឋកិច្ចមាន ដូចជាទំហំកំណត់ ១០,០០០ ហិកតា និងលក្ខខណ្ឌនៃការពិគ្រោះយោបល់ជាមុន និងយល់ព្រមជាមុនជាមួយអ្នករស់នៅលើដីនោះ។ មិនគិតដល់ពីការដាក់លក្ខខណ្ឌតម្រូវ ឬកំហិតនានាលើការជួលដីកសិកម្ម បែរជាសេចក្តីព្រាងច្បាប់ថ្មីនេះ និយាយឡើងវិញពីបទដ្ឋានគ្របដណ្តប់នៅក្នុងច្បាប់កម្មសិទ្ធិទាក់ទងនឹងការជួលទ្រព្យសម្បត្តិឯកជន មានដូចជាកាតព្វកិច្ចក្រោមលក្ខខណ្ឌនៃការជួល និងការបង់ថ្លៃឈ្នួលទាន់ពេលវេលានោះទៅវិញ។ ការជួលដីទំហំ ១០០,០០០ ហិកតាមានរយៈពេលដល់ ២០០ឆ្នាំ អាចធ្វើទៅបានយ៉ាងងាយស្រួលក្រោមលក្ខខណ្ឌថ្មីទាំងនេះ។

ការបញ្ចូលទៅក្នុងច្បាប់ នូវការដកចេញលក្ខខណ្ឌកំហិតសំខាន់ៗ លើដីសម្បទានដ៏ងាយយល់បាន ដើម្បីជាការនិយាយថា បង្កើនផលិតផលកសិកម្ម និរន្តរភាព និងអភិរក្សដីនោះ គឺមិនមែនជាអ្វីដែលគួរឲ្យភ្ញាក់ផ្អើលទេ។ រដ្ឋាភិបាលស្ថិតនៅក្រោមការគាបសង្កត់ដែលចេះតែកើនឡើងអោយគោរពតាមច្បាប់ដែលគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចនៅចំពោះមុខស្ថានការណ៍ នៃការកើនឡើងការផ្តល់ដីសម្បទានដោយមិនត្រឹមត្រូវ និងការកើនច្រើនឡើងនូវទំនាស់ដីធ្លីពាក់ព័ន្ធ ដែលត្រូវបានគេ

[២] មាត្រា ៤៩ នៃច្បាប់ភូមិបាលឆ្នាំ ២០១១

ផ្សព្វផ្សាយជាច្រើន[៣]។ ឧទាហរណ៍ ដីសម្បទានជាច្រើនដែលស្ថិតនៅជាប់ៗគ្នាត្រូវបានសរសេរចង ក្រងថា បានគ្រប់គ្រងដោយអ្នកទទួលផលប្រយោជន៍ដដែលៗ តាមរយៈចំណងគ្រួសារ ឬតាមរយៈ ក្រុមហ៊ុនស្រមោល។ ដោយមិនមានការដាក់កំហិតលើការជួលដីកសិកម្ម ដែលត្រូវបានគេបញ្ចូល ទៅក្នុងសេចក្តីព្រាងច្បាប់នេះទេ ការរិះគន់ទាំងនោះនឹងមិនអាចយកមកអនុវត្តបានទៀតទេ ហើយ រដ្ឋាភិបាលនឹងអាចជួលដីជាលក្ខណៈឯកជនអោយទៅក្រុមហ៊ុនដោយសេរី និងដោយមិនគិតអំពី ទំហំដី រយៈពេល ការយល់ព្រម កិច្ចព្រមព្រៀងលើការផ្លាស់ទីលំនៅថ្មី ឬការពិគ្រោះយោបល់ជាមុន ឡើយ។

## អជ្ញាប័ណ្ណបំលែងដី: ការបំផ្លាញចោលសិទ្ធិកម្មសិទ្ធិឯកជន

ក្រោមជំពូក ៩ អ្នកកាន់កាប់ដីឯកជនដែលចង់ចាប់ផ្តើម ឬឈប់ប្រើប្រាស់ដីរបស់ខ្លួន សម្រាប់គោលបំណងកសិកម្មត្រូវតែស្នើសុំអជ្ញាប័ណ្ណបំលែងដីទៅ "គណៈកម្មការបំលែងដីកសិកម្ម" ដែលបង្កើតថ្មី។ គណៈកម្មការមានអំណាចកំពូលក្នុងការចេញផ្តល់អោយ ឬបដិសេធផ្តល់អជ្ញាប័ណ្ណ បែបនេះ ឬសូម្បីតែមានអំណាចដាក់លក្ខខណ្ឌលើការប្រើប្រាស់ដីដែលបានស្នើឡើងនៅក្នុងសំណុំ បែបបទសុំអជ្ញាប័ណ្ណ។

នីតិវិធីនៃការដាក់សំណុំបែបបទមិនមានកំណត់នៅក្នុងច្បាប់ទេ ប៉ុន្តែទុកសម្រាប់អោយ ចេញតាមរយៈអនុក្រិត្យ។ លើសពីនេះទៀត នៅពេលដែលអ្នកកាន់កាប់ដី ចាប់ផ្តើមសកម្មភាព ការងារដូចដែលបានស្នើតាមពាក្យសុំអជ្ញាប័ណ្ណ ហើយដែលពាក្យសុំនោះនៅកំពុងតែរង់ចាំការសំរេច ច្បាប់នេះ និយាយសំដៅយ៉ាងច្បាស់ៗទៅរកបទល្មើសព្រហ្មទណ្ឌក្នុងជំពូក ១០។ ឧទាហរណ៍ បើតាមពង្រាងច្បាប់បច្ចុប្បន្ន បើសិនជាអ្នកទុកចោលសួនច្បារដំណាំតាមផ្ទះរបស់អ្នកដោយគ្មានដាំ ដំណាំទេ នោះអ្នកអាចត្រូវបានគេគិតថាបានប្រព្រឹត្តរំលោភលើជំពូករបស់ច្បាប់ដែលកំពុងតែពង្រាង នេះ។

---

[៣] ជាក់ស្តែង រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ទាក់ទងនឹងការពន្យាពេលការចេញសេចក្តីប្រកាសស្តីពីដីសម្បទានសេដ្ឋកិច្ច(ELCs) និងតម្រូវការការពិនិត្យមើលឡើងវិញ និងការដកហូតដីសម្បទានដែលមិនសមរម្យ។ វានៅតែត្រូវបានតាមដាន ថាតើអនុក្រឹតនេះនឹងបង្កើតឲ្យមានសកម្មភាពអ្វីឬក៏អត់។

**ផ្ទុយទៅវិញ: អាស្រ័យផលនៃកម្មសិទ្ធិក្រោមច្បាប់ភូមិបាលឆ្នាំ២០០១**

មាត្រា៨៥៖ កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុមានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយកុំឲ្យតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់។

មាត្រា៨៧៖ កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដីរាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួនលើកលែងតែមានច្បាប់ហាមឃាត់។ ការរៀបចំ ឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ស្រប តាមបញ្ញត្តិនៃផ្នែកទី៣ នៃជំពូកនេះ។

មាត្រា៨៨៖ កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចរៀបចំឬកែប្រែបានដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃទ្រព្យរបស់ខ្លួនស្របតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើតាមការកំណត់នៃច្បាប់។

មាត្រា៨៩៖ ចាត់ទុកជាការកែប្រែប្រភេទ ឬរចនាសម្ព័ន្ធដើមនៃទ្រព្យជាអចលនវត្ថុក្នុងន័យនៃច្បាប់នេះមានជាអាទិ៍ ការគាស់រានដី ការកាប់ ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីករុករក ការជីកយក ដីចេញ ការជីកអណ្តូងរ៉ែ ឬកន្លែងយកថ្ម ការរៀបចំឬការធ្វើឲ្យស្ងួតដែនវារីជាតិ ការរៀបចំដីកសិកម្មទៅជាទីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្មនិងការបង្កើតទីតាំងរោងចក្រ។

## តំបន់ជីវចម្រុះកសិកម្ម: ការច្បាមយកដីស្របតាមច្បាប់

ក្រោមមាត្រា ១២ សេចក្តីព្រាងច្បាប់នេះ អនុញ្ញាតឲ្យរដ្ឋាភិបាលមានឆន្ទានុសិទ្ធិ ដោយគ្មានដែនកំណត់ក្នុងការបង្កើត "តំបន់អភិរក្សជីវចម្រុះកសិកម្ម" ក្នុង "ដីកសិកម្មរបស់រដ្ឋ" ដោយមិនគិតអំពី ថាតើដីនោះត្រូវបាន "បែងចែកអោយទៅ និងប្រើប្រាស់ដោយបុគ្គល ឬអង្គការទាំងឡាយឡើយ"។ បើគម្រោងដីដែលត្រូវគេច្បាមយក គឺជាដីកាន់កាប់ដោយឯកជន សេចក្តីព្រាងច្បាប់នោះនិយាយសន្យាពីការផ្តល់ "សំណងសមរម្យ" ដែលមិនចងភ្ជាប់ទៅនឹងតម្លៃទីផ្សារ ឬ វិធានការជាក់លាក់ដទៃទេ ហើយដែលចំណុចនេះ គឺទុកអោយរដ្ឋាភិបាលជាអ្នកសំរេចទាំងស្រុង ហើយមិនមាននីតិវិធីនៃការប្តឹងជំទាស់ទេ។ ដោយហេតុថា រដ្ឋាភិបាលពិចារណាទៅលើដីទាំងអស់ ដែលមិនទាន់មានប័ណ្ណប្លង់ដីផ្លូវការ ថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះទេ។ ហើយដោយហេតុថា សិទ្ធិភោគៈអាចផ្តល់អោយអ្នករស់នៅលើដីនូវសិទ្ធិកម្មសិទ្ធិក្រោមច្បាប់ភូមិបាល បើទោះបីជាបុគ្គលនោះ មិនទាន់មានប្លង់ដីពេញលេញក៏ដោយ ក៏មាត្រាថ្មីនេះ គ្មានអ្វីក្រៅតែពីដើម្បីសម្រាប់ជាការច្បាមយកដីដោយស្របច្បាប់ប៉ុណ្ណោះនោះទេ។

ខណៈដែលតំបន់បែបនេះ ត្រូវបានបង្កើតឡើង រដ្ឋាភិបាលនាពេលនោះនឹងមានលទ្ធភាពអភិវឌ្ឍន៍ដីនោះទាំងស្រុងតាមតែលោកចង់បាន។

## មូលដ្ឋានច្បាប់ចំពោះការធ្វើអោយរួញរាដល់វិធីធ្វើកសិកម្មពនេចរ

ជំពូក៦ សំដៅគ្រប់គ្រងលើការប្រើប្រាស់ និងគ្រប់គ្រងដីកសិកម្មសហគមន៍តាមប្រពៃណី ប៉ុន្តែ បទបញ្ញត្តិភាគច្រើនលើសលុបក្នុងជំពូកនេះ ហាក់ដូចជាព្រាងឡើងមក ដើម្បីលើកទឹកចិត្ត អោយបោះបង់វិធីធ្វើកសិកម្មពនេចរ។ នេះមិនមែនជាអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារការជំទាស់ យ៉ាងច្បាស់របស់រដ្ឋាភិបាលចំពោះប្រពៃណីនេះដែលជាវិធីនៃការកែប្រែធនធានដីដោយនិរន្តរភាព។

មាត្រា ២៧ និយាយថា ការទទួលស្គាល់កសិកម្មពនេចរ ដែលក្នុងឃ្លានេះផ្ទាល់រួមមាននូវ ទម្រង់កសិកម្មផ្សេងៗជាច្រើនដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់នោះ ថាជាទំរង់ដែលធ្វើ ទៅបាន ដោយតម្រូវអោយរកមើលជាដំបូងអំពីវិធីដែលគេកំពុងតែប្រតិបត្តិការក្នុងតំបន់។ បញ្ហានេះ តែមួយ គឺជាការលំបាកដើម្បីនឹងធ្វើអោយសម្រេចបានណាស់ ដោយសារថា មន្ត្រីកម្ពុជាបានហាម ឃាត់សហគមន៍ជនជាតិដើមភាគតិច ម្តងហើយម្តងទៀតពីការបន្តប្រើប្រាស់វិធីបែបប្រពៃណីទាំង នេះ ហើយសូម្បីតែបានថ្លែងថា កសិកម្មពនេចរមិនមានអនុញ្ញាតទៀតទេក្នុងប្រទេសកម្ពុជា។[៤]

ជាការសំខាន់បន្ថែមទៀតនោះ គឺជំពូក៦ ផ្តល់អោយអគ្គនាយកដ្ឋានកសិកម្មដឹកនាំកិច្ចខិតខំ ប្រឹងប្រែង ដើម្បីផ្លាស់ប្តូរវិធីកសិកម្មដែលកាន់តែសមស្របសម្រាប់កសិពាណិជ្ជកម្មនៅកន្លែងណា ដែលមានភស្តុតាងច្បាស់លាស់ បង្ហាញដល់អគ្គនាយកដ្ឋានដីកសិកម្ម ឬនៅក្នុងវេទិកាណាដែល សហគមន៍ "មានបំណងផ្លាស់ប្តូរចេញពីកសិកម្មពនេចរ ដើម្បីចាប់យកឱកាសទីផ្សារខាងផ្នែក កសិកម្ម"។ បទបញ្ញត្តិនេះ ផ្តល់នូវការការពារយ៉ាងគ្រប់គ្រាន់ដល់មន្ត្រីរដ្ឋាភិបាលដែលបានស្វះស្វែង រួចហើយដើម្បីបង្ខំសហគមន៍ដែលអនុវត្តវិធីកសិកម្មជាប្រពៃណីអោយបោះបង់ចោលវិធីទាំងនោះ។

## ក្នុងករណីមានជម្លោះទាក់ទងនឹងកច្ចសន្យា ឥកសិករជាអ្នកចាញ់ទាំងស្រុង

ជំពូក ៧ បង្កើតចេញនូវបទវិន័យពិសេសជាក់លាក់យ៉ាងចំលែក សម្រាប់កសិកម្មតាមកិច្ច សន្យា។ មិនមែនមានតែប្រធានបទនេះទេ ដែលហាក់បីដូចជាមិនទាក់ទងនឹងគោលបំណងរបស់ សេចក្តីព្រាងច្បាប់នេះ ប៉ុន្តែបានគ្របដណ្តប់រួចហើយ នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ដែលដាក់បានអោយអនុវត្តនាពេលថ្មីៗនេះ។

ទោះជាយ៉ាងណាក៏ដោយ មិនមានការដោះសារនោះទេ ចំពោះមាត្រា ៣៧នេះ ដែលចែងថា បើសិនជាមានជម្លោះទាក់ទងនឹងកិច្ចសន្យារវាង "ភាគីផលិត" (កសិករ) និង "អ្នកទិញ" មិនអាចដោះ ស្រាយបាននោះ "ភាគីទាំងពីរត្រូវអនុវត្តយន្តការដូចមានចែងក្នុងមាត្រា៣៥ នៃច្បាប់នេះ"។

---

[៤] ប្រភពព័ត៌មាន អង្គការលីកាដូ មានអំណះអំណាងអំពីសេចក្តីថ្លែងបែបនេះរបស់មន្ត្រីនានានៅក្នុងឱកាសជាច្រើន។

មាត្រា ៣៥ និយាយទាំងស្រុងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទិញ ដែលប្រឆាំងគ្នានឹងមាត្រា ៣៤ ដែលនិយាយពីសិទ្ធិរបស់កសិករ។ ក្រោមមាត្រា៣៥ អ្នកទិញត្រូវបានផ្តល់អំណាចអោយ "កំណត់មុខទំនិញ ដូចជា បរិមាណ គុណភាព ទីកន្លែង និងថ្ងៃខែត្រូវបញ្ជូន និងទទួលយកនូវផលិតផល"។ ការមានទំនាក់ទំនងមិនស្មើភាពគ្នាកាន់តែច្រើនឡើងអាចធ្វើអោយមានការពិបាកក្នុងការគិតអំពីអ្វីដែលនឹងអាចកើតឡើង។ ជំពូកនេះ មិននិយាយយោងទៅរកការដោះស្រាយជម្លោះទាក់ទងនឹងកិច្ចសន្យានៅតុលាការ ឬក៏តាមរយៈស្ថាប័នណាផ្សេងដែលអព្យាក្រឹត្យ ឬស្ថាប័នរដ្ឋបាលនោះទេ។

## ការសរសេរមិនច្បាស់លាស់ថា សកម្មភាពកសិកម្ម "មាននិរន្តរភាព" លើដីឯកជន

មាត្រា៨ តម្រូវថា បុគ្គលគ្រប់រូប ឬនីតិបុគ្គលទាំងអស់ ដែលអនុវត្ត "ការងារកសិកម្មនៅលើដីកន្លែងណាមួយនោះ ត្រូវមានភារកិច្ចអនុវត្តសកម្មភាពនោះប្រកបដោយនិរន្តរភាព"។ ពាក្យ "និរន្តរភាព" មិនត្រូវបានកំណត់និយមន័យច្បាស់លាស់ទេ និងមិនមានហេតុផលសំអាងណាមួយសម្រាប់ដាក់បន្ទុកមិនច្បាស់លាស់ទៅលើអ្នកកាន់កាប់ដីឯកជនដែរ។ ហើយម្តងទៀត ក្រោមជំពូក ១០ ការប្រព្រឹត្តខុសពីវិធានការ "មាននិរន្តរភាព" កំណត់ដោយរដ្ឋាភិបាលលើដីកាន់កាប់ ដោយឯកជនអាចនាំទៅដល់ការដាក់ទោសពីបទព្រហ្មទណ្ឌធ្ងន់ធ្ងរ ដែលរួមមានទាំងការដាក់អោយជាប់ពន្ធនាគារផងដែរ។

## អនុសាសន៍

ដោយសារតែសេចក្តីព្រាងច្បាប់នេះ មានការគំរាមកំហែងជាខ្លាំងចំពោះសិទ្ធិខាងដីធ្លីជាឯកជន អង្គការលីកាដូ សូមផ្តល់អនុសាសន៍សូមមេត្តាកែប្រែច្បាប់នេះលើចំណុចជាច្រើន:

- បទបញ្ញត្តិអំពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែដកចេញពីច្បាប់នេះទាំងស្រុង។ រដ្ឋាភិបាលលោកគួរតែលើកទឹកចិត្តដល់ការអនុវត្តល្អលើដីកសិកម្ម ដោយបង្កើតអោយមានជាឧទាហរណ៍ផ្សេងៗ និងតាមរយៈគ្រឿងជម្រុញទឹកចិត្តជាវិជ្ជមាននានា មិនមែនដោយការយកកសិករទៅដាក់ពន្ធនាគារនោះទេ។
- ច្បាប់គួរតែបញ្ជាក់ច្បាស់ថា មិនមានអ្នកកាន់កាប់ដី ដែលអាចត្រូវគេបង្ខំអោយចូលរួមក្នុងតំបន់អភិវឌ្ឍន៍កសិកម្មទេ ដោយទោះបីជាអ្នកជិតខាងរបស់អ្នកទាំងនោះជ្រើសរើសចូលរួមក៏ដោយ។
- ច្បាប់ត្រូវតែបញ្ចូលការណែនាំបញ្ជាក់យ៉ាងច្បាស់លាស់អំពីមាតិកា និងគោលបំណងនៃផែនការតំបន់អភិវឌ្ឍន៍កសិកម្ម និងដំណើរការពិគ្រោះយោបល់ជាមុន។ ដំណាក់កាលពិគ្រោះយោបល់គួរតែត្រូវតម្រូវអោយបញ្ចូលការពិភាក្សា អំពីផលវិបាកអវិជ្ជមានជា

សក្តានុពលនៃការចូលរួមនៅក្នុងតំបន់ទាំងនេះ គឺមិនមែនគ្រាន់តែនិយាយអំពីផលប្រយោជន៍នោះទេ។

- ដោយច្បាប់នេះអះអាងថា តំបន់អភិវឌ្ឍន៍កសិកម្ម មានគោលបំណងជួយដល់កសិករខ្នាតតូច ដូច្នេះការបង្កើតតំបន់ទាំងនេះគួរតែចេញមកពីកសិករខ្លួនគេផ្ទាល់ មិនមែនចេញមកតែពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងស្រុងតែម្នាក់ឯងនោះទេ។
- ច្បាប់ត្រូវតែកំណត់អោយបានច្បាស់លាស់អំពីកាតព្វកិច្ច ដែលមានទាក់ទងនឹងការបាត់បង់គុណភាពដី និងឱនភាពដី ក៏ដូចជានិយមន័យជាក់លាក់នៃពាក្យ "បាត់បង់គុណភាព" និង"ឱនភាព"។ ត្រូវតែមានការរៀបរាប់នៅក្នុងច្បាប់ផងដែរអំពីនីតិវិធី (ដំណើរការ) ប្តឹងជំទាស់។ ដីឧស្សាហកម្មមិនត្រូវមានការលើកលែងចេញពីកំហិតនានា ដែលបានដាក់លើអ្នកកាន់កាប់ដីឯកជន ទាក់ទងនឹងការអភិរក្សធនធានដីទេ។ ក្រោមបទបញ្ញត្តិនេះ អ្នកកាន់កាប់ដីឯកជនក៏មិនត្រូវជាអ្នកដែលត្រូវចំណាយផ្ទាល់ខ្លួនដោយមិនសមហេតុមិនសមផលនោះដែរទេ។
- ច្បាប់ថ្មីនេះ គួរតែមិនត្រូវបញ្ចូលបទបញ្ញត្តិណាដែលទាក់ទងនឹងការជួលដីកសិកម្មនោះទេ។ ពីព្រោះបទបញ្ញត្តិបែបនេះ មិនស្របជាមួយនឹងគោលបំណងដែលមានអះអាងក្នុងច្បាប់ថ្មីនេះទេ ហើយម្យ៉ាងទៀតបទបញ្ញត្តិដែលទាក់ទងនឹងការជួលដីកសិកម្មមានចែងគ្រប់គ្រាន់ដោយច្បាប់ជាធរមានយ៉ាងច្រើនរួចហើយ។ ច្បាប់ថ្មីនេះ មិនត្រូវបញ្ចូលនូវការប៉ុនប៉ងដ៏ច្បាស់ក្រលែត ដើម្បីដកចេញការការពារ និងលក្ខខណ្ឌតម្រូវសម្រាប់ដីសម្បទានសេដ្ឋកិច្ចនោះដែរ។
- បទបញ្ញត្តិទាក់ទងនឹងអជ្ញាប័ណ្ណបំលែងដី ចំពោះម្ចាស់ដីឯកជនគួរតែត្រូវដកចេញផងដែរ។
- ដកចេញនូវជំពូក ទាក់ទងនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា។
- សូមឲ្យអ្នកពង្រាងច្បាប់នេះ មេត្តាពិនិត្យឡើងវិញ ថាតើមានការត្រូវការនោះទេនូវការបង្កើតអោយមាននូវការិយាធិបតេយ្យបន្ថែមក្នុងទម្រង់ជាគណៈកម្មការអន្តរក្រសួងថ្មីធំៗមួយចំនួនទៀត ដោយមានភារកិច្ចដែលមិនបានកំណត់ច្បាស់លាស់ និងមានតួនាទីត្រួតលើគ្នា?

ចំពោះមុខនៃកង្វល់ទាំងអស់ខាងលើ អង្គការលីកាដូ សូមសំណូមពរដោយទទូចផងដែរថា សូមរដ្ឋាភិបាល លោកមេត្តាគួរតែបង្ហាញអោយបានច្បាស់លាស់អំពីសេចក្តីត្រូវការ និងគោលបំណងជាក់លាក់នៃសេចក្តីព្រាងច្បាប់ថ្មីនេះ មុនពេលដំណើរការទៅមុខទៀតជាមួយនឹងការមានកិច្ចពិគ្រោះយោបល់ និងការកែប្រែ។

□□□